# បច្ចុប្បន្នភាព
## ការធ្វើអនុលោមភាព
# នៃបទដ្ឋានគតិយុត្តិក្នុងបរិការណ៍ឆ្លងរាលដាល នៃជំងឺកូវីដ ១៩ និង វិធានការបិទខ្ទប់ភូមិសាស្ត្រ រាជធានី និងក្រុងតាខ្មៅ ចំពោះសង្គមស៊ីវិល

បទបង្ហាញៈ លោក វី សុវណ្ណា
ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងការតស៊ូមតិ

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០២១

# កម្មវត្ថុ

- ផ្តល់មូលដ្ឋានពិចារណាក្នុងទិដ្ឋភាពគតិយុត្តិដើម្បី ឆ្លុះបញ្ចាំងលើការដាក់ចេញនូវវិធានការរដ្ឋបាល និងវិធានការចាំបាច់នានា ឆ្លើយតបនឹងជំងឺកូវីដ ១៩ និងទទ្បីករណ៍លើកកម្ពស់សិទ្ធិជាមូលដ្ឋានក្នុងបរិបទកូវីដ ១៩ សម្រាប់សង្គមស៊ីវិលនៅកម្ពុជា
- ធ្វើបច្ចុប្បន្នភាពទិដ្ឋភាពច្បាប់ជាពិសេសវិធានការរដ្ឋបាលថ្មីៗ ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ដែលធ្វើឱ្យមានការជះឥទ្ធិពលដោយផ្ទាល់ដល់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ជាពិសេសកាតព្វកិច្ចសារពើពន្ធ និងរបបសន្តិសុខសង្គម
- ការពង្រឹងចំណងសាមគ្គីភាពនៃសង្គមស៊ីវិលដើម្បីបន្តបម្រើឧត្តមប្រយោជន៍ប្រជាពលរដ្ឋក្នុងស្ថានភាពរាតត្បាតនៃជំងឺកូវីដ ១៩ និងការតស៊ូមតិរួមគ្នានៅពេលបន្ទាប់ ។

# ច្បាប់ & លិខិតបទដ្ឋានគតិយុត្តិដើម្បីទប់ស្កាត់ការឆ្លង រាលដាលនៃជំងឺកូវីដ ១៩

1. រដ្ឋធម្មនុញ្ញ (មាត្រា ៥២ - សុខុមាលភាពសាធារណៈ & ការពារសិទ្ធិ និង សណ្តាប់ធ្នាប់សាធារណៈ)
2. ច្បាប់ស្តីពីការប្រកាសដាក់ប្រទេសស្ថិតនៅក្នុងស្ថានភាពអាសន្ន ។ មូលហេតុ - ថិរៈវេលា - វិធានការ
   - ❖ អនុទ្បោមភាពនៃមាត្រា ២២ រដ្ឋធម្មនុញ្ញកម្ពុជា
   - ❖ កាតព្វកិច្ចជូនដំណឹងទៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ
3. ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ដទៃផ្សេងទៀត (ច្បាប់កូវីដ ១៩)
   - វិធានការ - កម្រិតសិទ្ធិដើរហើរ - សិទ្ធិជួបជុំ - ចត្តាឡីស័ក - កម្រិតសកម្មភាពការងារ & មុខរបរ - កំណែន & ជម្លៀសប្រជាពលរដ្ឋ - ការដកហូត គ្រប់គ្រង និងចាត់ចែកទ្រព្យសម្បត្តិ - ការបិទទីតាំង - ការតាមដាន & ឃ្លាំមើលតាមគ្រប់មធ្យោបាយ - កម្រិតការចែកចាយព័ត៌មាន
   - ទោស & ការផ្តល់សិទ្ធិអំណាចធំធេងដល់រដ្ឋាភិបាល

# លិខិតបទដ្ឋានគតិយុត្តិ វិធានការរដ្ឋបាលដោយរាជរដ្ឋាភិបាលកម្ពុជា

- ការរឹតត្បិត ឬហាមឃាត់ការធ្វើដំណើរ
- ការជួបជុំ និងការប្រមូលផ្តុំមនុស្ស
- ការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរ
- ការបិទខ្ទប់តំបន់ ឬទីកន្លែងមួយចំនួនដែលមានការឆ្លង
- ការរឹតត្បឹត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លង

បញ្ជាក់៖ ការប្រើប្រាស់វិពាត់ផ្តៅ និង ការតាមដានតាមបណ្តាញសង្គមចំពោះសកម្មភាពផឹកស៊ីសប្បាយបង្កួតគ្នារបស់អាជ្ញាធរមិនសមត្ថកិច្ច និងកងកម្លាំងអនុវត្តច្បាប់ ។

# អនុលោមភាព

# នៃភាគច្រើនកិច្ចសារពើពន្ធក្នុងបរិការណ៍ឆ្លងរាលដាល នៃជំងឺកូវីដ ១៩ និង វិធានការបិទខ្ទប់ភូមិសាស្ត្រ រាជធានី និងក្រុងតាខ្មៅ

# ចំណាត់ថ្នាក់អ្នកជាប់ពន្ធចំពោះអង្គការ និងសមាគម

1. សមាគម និងអង្គការមិនមែនរដ្ឋាភិបាលចុះបញ្ជីជានីតិបុគ្គល និង ស្ថិតនៅក្នុងប្រភេទអ្នកជាប់ពន្ធមធ្យម ។
2. សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសកម្មភាពដោយឡែក និងមិនស្ថិតក្នុងគោលដៅសុទ្ធសាធរបស់ខ្លួនខាងសាសនា សប្បុរសធម៌ វិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬអប់រំ (មិនត្រូវបានប្រើជាប្រយោជន៍ឯកជន និង ត្រូវលើកលែងពន្ធ) ៖ ត្រូវចាត់ទុកថាធ្វើសកម្មភាពអាជីវកម្មដោយឡែក ដែលត្រូវបានចាត់ទុកជាសហគ្រាសឯកបុគ្គល និងត្រូវចុះបញ្ជីពន្ធដារ តាមកម្រិតផលរបរ និងប្រភេទអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ដែលភាគច្រើនស្ថិតក្នុងចំណាត់ថ្នាក់ អ្នកជាប់ពន្ធតូច ដែលមានលក្ខខណ្ឌផលរបរប្រចាំឆ្នាំពី ២៥០ លានរៀលទៅ ៧០០ លានរៀល ។

# លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែតាមអនឡាញសម្រាប់ អង្គការ និងសមាគម

អគ្គនាយកដ្ឋានពន្ធដារបានជូនដំណឹងដល់អ្នកជាប់ពន្ធ ភ្នាក់ងារសេវាកម្មពន្ធដារឆ្លើយតបនឹងវិធានការបិទខ្ទប់នូវភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩

1. លើកទឹកចិត្តអ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារនៅក្នុងបរិការណ៍នៃការរាតត្បាតជំងឺកូវីដ ១៩ និងការបិទខ្ទប់ភូមិសាស្ត្រមួយចំនួន បំពេញលិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែតាមអនឡាញ (Online) ការប្រើប្រាស់ E-mail ឬមធ្យោបាយអេឡិចត្រូនិចដើម្បីបញ្ជូន និងទទួលឯកសារ Soft Copy ។
2. អ្នកជាប់ពន្ធអាចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធតាមជម្រើសចំនួន ០២៖
   - ❖ អង្គការ និងសមាគម បំពេញ និងដាក់លិខិតប្រកាសប្រចាំខែ ដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធប្រចាំខែ (E-Filing) និងធ្វើការទូទាត់ប្រាក់ពន្ធតាមអនឡាញ (E-Payment) ។ សម្រាប់អាជីវកម្មដោយឡែកបើស្ថិនក្នុងចំណាត់ថ្នាក់អ្នកជាប់ពន្ធតូច អាចបំពេញ និងដាក់លិខិតប្រកាសប្រចាំខែតាមរយៈកម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefilng App)
   - ❖ ក្នុងករណី អង្គការ ឬ សមាគមមិនទាន់មានលទ្ធភាពប្រើ E-Filing ឬ GDT Tax Prefiling App អាចបំពេញលិខិតប្រកាសពន្ធប្រចាំខែដោយដៃ និងបង់ប្រាក់ពន្ធតាម E-Payment រួចស្កេនលិខិតប្រកាស និងបង្កាន់ដៃបញ្ជាក់តាមរយៈប្រព័ន្ធបញ្ជូនឯកសារអេឡិចត្រូនិច (E-Document) ។

# បទអន្តរាគមន៍សម្រួលដំណើរការនៃការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ

*សវតា*

1. សេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ ១៩ ។
   - ការបិទខ្ទប់នេះ គឺហាមឃាត់មិនឱ្យធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ប្រសិនបើគ្មានការចាំបាច់ ។
   - ការហាមឃាត់ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរនៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ដែលបានហាមឃាត់ ។
2. ករណីលើកលែង៖ សកម្មភាពការងាររបស់កងកម្លាំងប្រដាប់អាវុធ, រដ្ឋបាលថ្នាក់ក្រោមជាតិ, សេវាសង្គ្រោះបន្ទាន់, សេវាសុខាភិបាល និងឱសថស្ថាន, សកម្មភាពទាក់ទងផលិតកម្មម្ហូបអាហារ និងគ្រឿងឧបភោគបរិភោគ, សេវាកម្មដឹកជញ្ជូន, សេវាជាតម្រូវការចាំបាច់ប្រចាំថ្ងៃ - ធនាគារ ប្រៃសនីយ៍ ទូរគមនាគមន៍
3. រាល់ការធ្វើដំណើរមកបំពេញការងារត្រូវមានលិខិតអនុញ្ញាតធ្វើដំណើរដោយគណៈកម្មការប្រតិបត្តិ នៃ គណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ (គ.ប.ខ) ។

# បទអន្តរាគមន៍សម្រួលដំណើរការនៃការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ (ត)

*បទអន្តរាគមន៍របស់អគ្គនាយកដ្ឋានពន្ធដារ*

1. សម្រាប់ប្រភេទសកម្មភាពដែលត្រូវបានអនុញ្ញាតឱ្យបន្តសកម្មភាពក្នុងកំឡុងពេលនៃការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ - ការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែមីនាដែលត្រូវធ្វើនៅក្នុងខែមេសា នឹងត្រូវពន្យាររហូតដល់ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០២១ ។
2. អង្គការ និង/ឬ សមាគម ស្ថិតនៅក្នុងប្រភេទសកម្មភាពដែលត្រូវបានហាមឃាត់ក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ - ការដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែមីនា ដែលត្រូវធ្វើនៅក្នុងខែ មេសា នឹងត្រូវពន្យារពេលរហូតដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២១ ។

អគ្គនាយកដ្ឋានពន្ធដារបានរៀបចំក្រុមការងារសេវាគាំទ្រ (e-Tax Service) និងមជ្ឈមណ្ឌល Call Center 1277 ដើម្បីដោះស្រាយបញ្ហាក្នុងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ និងការឆ្លើយចម្ងល់នានា ។

*បន្ថែមនូវការធ្វើ Survey របស់អង្គការ គ.ស.ក*

# ភាតព្វកិច្ចបង់ភាគទាន និងផ្ដល់របាយការណ៍ទៅ ប.ស.ស

1. បេឡាជាតិរបបសន្តិសុខសង្គមបានលើកពេលកំណត់ការបង់ភាគទាន និងផ្ដល់របាយការណ៍កម្មករនិយោជិតមក ប.ស.ស ដោយមិនមានការផាកពិន័យ ប៉ុន្តែត្រូវរៀបចំឯកសារឱ្យបានលឿនបន្ទាប់ពីចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ ។
2. ប្រព័ន្ធទូរស័ព្ទផ្ដល់ព័ត៌មានលេខ ១២៨៦ ដំណើរការជាធម្មតាវិញហើយ ២៤ ម៉ោង និង ពេញ ១ សប្ដាហ៍ ។

# និរាករណ៍គោលនយោបាយអន្តរាគមន៍ជំនួយសង្គមដើម្បីគាំពារប្រជាពលរដ្ឋដែលខេគ្រោះ ឬរងផលប៉ះពាល់ធ្ងន់ធ្ងរពីជំងឺកូវីដ ១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១

1. វិសាលភាពនៃវិធានការជំនួយសង្គមៈ ១. គ្រួសារមានជីវភាពលំបាក រស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលបានអនុវត្តវិធានការបិទខ្ទប់ ២. គ្រួសារមានសមាជិកទទួលរងកូវីដ ១៩ ប៉ុន្តែមិនមានអ្នកស្លាប់នៅទូទាំងប្រទេស និង ៣. គ្រួសារមានសមាជិកស្លាប់ដោយសារជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ។
2. ត្រូវបាននិរាករណ៍ ។

# សូមអរគុណ...